Australian Government

Department of Immigration and Citizenship





# យើងអាចជួយលោកអ្នករៀនភាសាអង់គ្លេស

## កម្មវិធីភាសាអង់គ្លេសសំរាប់ជនប្រវេសន៍ពេញវ័យ

### ហេតុអ្វីបានជាខ្ញុំគួរតែរៀនភាសាអង់គ្លេស?

ឥឡូវអ្នកនៅក្នុងប្រទេសអូស្ត្រាលី វាមានសារៈសំខាន់ណាស់សំរាប់អ្នកក្នុងការរៀនភាសាអង់គ្លេស។

អង់គ្លេសគឺជាភាសាជាតិរបស់ប្រទេសអូស្ត្រាលី។ប្រជាជននៅប្រទេសអូស្ត្រាលីនិយាយជាច្រើនភាសា ប៉ុន្តែ ដើម្បីចូលរួមក្នុងការរស់នៅក្នុងប្រទេសអូស្ត្រាលី អ្នកត្រូវតែចេះនិយាយ និង យល់ពីភាសាអង់គ្លេស។ ប្រសិនបើមិនចេះភាសារអង់គ្លេសទេ អ្នកនឹងពិបាកក្នុងការស្វែងរកការងារ ហើយអ្នកនឹងក្លាយទៅជាមនុស្សដែលគ្មានទំនាក់ទំនងនឹងអ្នកដ៏ទៃ។ លោកអ្នកក៏ត្រូវការភាសាអង់គ្លេសជាចាំបាច់ដែរប្រសិនបើលោកអ្នកមានបំណងក្លាយទៅជាពលរដ្ឋអូស្ត្រាលី

### តើអ្វីជាកម្មវិធីភាសាអង់គ្លេសសំរាប់ជនប្រវេសន៍ពេញវ័យ?

កម្មវិធីនេះត្រូវបានស្គាល់ថា AMEP ផ្តល់ការសិក្សាមូលដ្ឋាននៅក្នុងភាសារអង់គ្លេសដើម្បីជួយដល់ជនប្រវេសន៍ពេញវ័យនិងជនភៀសខ្លួនដែលមានសិទ្ធិតាំងលំនៅបាននៅក្នុងប្រទេសអូស្ត្រាលី។

AMEP នឹងបង្រៀនលោកអ្នកច្រើនជាងត្រឹមតែបង្រៀនភាសាអង់គ្លេស។ លោកអ្នកនឹងរៀនអំពី សង្គម វប្បធម៌ និង ប្រពៃណី របស់អូស្ត្រាលីថែមទៀតផង។ អ្នកនឹងជួបអ្នកចំណូលថ្មីដ៏ទៃទៀតដែលជាអ្នកធ្លាប់មានបទពិសោធន៍ និង គោលដៅដូច្នេះដែរ ហើយលោកអ្នកប្រហែលជានឹងអាចបង្កើតបានមិត្តថ្មីជាច្រើនទៀត។

AMEP គឺជាកម្មវិធីដែលផ្តល់មូលនីធិដោយរដ្ឋាភិបាលអូស្ត្រាលី។

### តើខ្ញុំមានសិទ្ធិទទួលយកកម្មវិធីឬទេ?

លោកអ្នកប្រហែលជាមានសិទ្ធិទទួលបានប្រសិនបើអ្នកជាជនប្រវេសន៍ ឬ ជាជនភៀសខ្លួន ដែលតាំងលំនៅក្នុងប្រទេសអូស្ត្រាលី ហើយបានទទួលនូវទិដ្ឋាការស្នាក់នៅអចិន្ត្រៃ និង ចេះនិយាយភាសាអង់គ្លេសបន្តិចបន្តួចរឺអត់សោះ។

ប្រវេសន៍ជនមួយចំនួនដែលមានការផ្តល់ទិដ្ឋាការបណ្តោះអាសន្នប្រហែលជាអាចមានសិទ្ធិ ចូលរួមក្នុងកម្មវិធី ហើយនិង យុវជននៅចន្លោះអាយុ ១៥ និង ១៧ ឆ្នាំក៏អាចនឹងចូលរួមកម្មវិធីបានផងដែរ។

អ្នកចាំបាច់ត្រូវចុះឈ្មោះជាមួយស្ថាប័នផ្តល់កិច្ចបំរើ AMEP ណាមួយក្នុងអំឡុងពេល៦ខែនៃការចូលមកដល់ ប្រទេសអូស្ត្រាលី ឬ ទទួលសិទ្ធិជាពលរដ្ឋអចិន្ត្រៃ។អ្នកគួរតែចាប់ផ្តើមថ្នាក់ភាសារអង់គ្លេសក្នុងអំឡុងពេលមួយឆ្នាំ។

លោកអ្នកអាចរៀនភាសាអង់គ្លេសជាមួយ AMEP រហូតដល់ទៅ៥១០ម៉ោង នៃវគ្គរៀនភាសាអង់គ្លេសសំរាប់ប្រាំឆ្នាំចាប់ពីថ្ងៃនៃការផ្តើមធ្វើទិដ្ឋាការរបស់ពួកគេ ឬ ចំនួនម៉ោងចាំបាច់ដើម្បីសំរេចបាននូវកំរិតនៃភាសាអង់គ្លេស (មួយណាដែលមកដល់មុន)។

លោកអ្នកអាចនឹងមានសិទ្ធិគ្រប់គ្រាន់ក្នុងការរៀនបន្ថែមប្រសិនបើលោកអ្នកមានតំរូវការចាំបាច់ ព្រោះជួបការពិបាកលើបទពិសោធន៍មុនពេលធ្វើការ ( ឧទាហរណ៍ ត្រូវរងអំពើទារុណ្ឌកម្ម និង ការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ) ឬការសិក្សានៅមានកំរិត។

លើសពីនេះទៀត ការរៀនបន្ថែមគឺផ្តល់សំរាប់ អតិថិជន AMEP តាមរយៈកម្មវិធី ផ្លូវឆ្ពោះទៅកាន់ការងារ និង ហ្វឹកហ្វឺន(SLPET) ។ SLPET ផ្តល់ជូនសមាជិកនូវការងារដោយយកចិត្តទុកដាក់ទៅលើវគ្គសិក្សាដោយជួយទំនុកបំរុងពួកគេដើម្បីរៀនអាជីពពិតប្រាកដ ដោយភាសាអង់គ្លេសក្នុងការដែលសំរេចបាននូវការស៊ាំនឹងច្បាប់កន្លែងធ្វើការ និង ការហ្វឹកហ្វឺននៅប្រទេសអូស្ត្រាលី។

### នេះនឹងត្រូវចំណាយអស់ប៉ុន្មាន?

គ្មានការបង់ថ្លៃសំរាប់មនុស្សស្ទើរទាំងអស់ដែលមានសិទ្ធិទៅសិក្សាតាមរយៈកម្មវិធី។

### តើអ្នកណានឹងបង្រៀនខ្ញុំ?

អង្គការក្នុងតំបន់ ត្រូវបានហៅថាស្ថាប័នផ្តល់កិច្ចបំរើ ផ្តល់ការបង្រៀន AMEP ។ ស្ថាប័នផ្តល់កិច្ចបំរើទាំងនេះជួលគ្រូបង្រៀនដែលជាអ្នកមានការបណ្តុះបណ្តាលផ្នែកបង្រៀនភាសាអង់គ្លេសទៅដល់អ្នកនិយាយភាសាផ្សេងៗទៀត។

ស្ថាប័នផ្តល់កិច្ចបំរើក្នុងតំបន់របស់លោកអ្នកនឹងប្រាប់អ្នកថាតើលោកអ្នកមានសិទ្ធិ សំរាប់កម្មវិធីឬទេ។ពួកគេអាចណែនាំផ្លូវដែលល្អបំផុតសំរាប់លោកអ្នកដើម្បីរៀនភាសាអង់គ្លេស។

ពួកគេអាចស្វែងរកការយល់ព្រមសំរាប់អ្នកដើម្បីពន្យាពេលនៃការចាប់ផ្តើមចូលរៀនរបស់លោកអ្នកប្រសិនបើអ្នកត្រូវការសំរាប់ហេតុផលគ្រួសារ ឬ ការងារ។

ស្ថាប័នផ្តល់កិច្ចបំរើរបស់លោកអ្នកនឹងណែនាំលោកអ្នកនូវវគ្គសិក្សាណាមួយដែលត្រូវទៅតាមតំរូវការរបស់លោកអ្នក។ពួកគេនឹងធ្វើយ៉ាង នេះដោយផ្អែកលើការងារ កាលៈទេសៈគ្រួសារ និង កំរិតភាសារអង់គ្លេសបច្ចុប្បន្នរបស់លោកអ្នក។ពួកគេក៏អាចជួយលោកអ្នករៀបចំគំរោងសិក្សានៅអនាគតផងដែរ។

## តើអ្នកណាមើលថែកូនរបស់ខ្ញុំក្នុងពេលខ្ញុំកំពុងរៀនភាសាអង់គ្លេស?

ស្ថាប័នផ្តល់កិច្ចបំរើ AMEP របស់លោកអ្នកអាចរៀបចំអ្នកមើលថែក្មេងដោយឥតគិតថ្លៃ សំរាប់កូនរបស់លោកអ្នកនៅពេលដែលអ្នករៀននៅសាលា។ ការមើលថែក្មេងឥតគិតថ្លៃគឺផ្តល់អោយសំរាប់តែក្មេងណាដែលក្រោមអាយុចូលសាលា ហើយនឹងពេល ដែលអ្នករៀននៅសាលាតែប៉ុណ្ណោះ។

សំពត៌មានបន្ថែមសូមសួរ មជ្ឈមណ្ឌល AMEP របស់លោកអ្នកសំរាប់សន្លឹកពត៌មានអំពីការមើលថែកុមារ។

## តើខ្ញុំនឹងរៀននៅទីកន្លែងណា ?

ស្ថាប័នផ្តល់កិច្ចបំរើជូនវគ្គសិក្សាពេញម៉ោង និង មិនពេញម៉ោងនៅម៉ោងផ្សេងៗគ្នា(ពេលថ្ងៃ ពេលរសៀល និង ចុងសប្តាហ៍) ហើយនឹងទីកន្លែងផ្សេងៗគ្នារួមមាន សាលារៀន វិទ្យាស្ថាន និង មជ្ឈមណ្ឌលសមាគមន៍ ដែលមានដូចជា វិហារសាសនាគ្រិស្ត និង វិហារអ៊ីស្លាម ។

ស្ថាប័នផ្តល់កិច្ចបំរើផ្តល់ជូនវគ្គសិក្សានៅតាមជនបទ និង នៅតាមតំបន់ភូមិភាគអោយបានល្អដូចនៅទីក្រុងធំដែរ។

## តើអ្វីកើតឡើងប្រសិនបើខ្ញុំមិនអាចចូលរៀនបានទេ?

### រៀនពីចំងាយ

AMEP មានកម្មវិធីរៀនពីចំងាយ។ ស្ថាប័នផ្តល់កិច្ចបំរើ AMEP របស់លោកអ្នក អាចអោយអ្នកនូវពត៌មានជាច្រើនទៀត ហើយនិង ការណែនាំទៅលើវគ្គសិក្សាទាំងនេះ។

កម្មវិធីត្រូវបានចាត់ចែងផ្ទាល់នៅតាមអ៊ីនធឺណិត ឬ តាមរយៈកញ្ចប់អត្ថបទនិង ឧបករណ៍សំលេងតៗគ្នាជាលំដាប់ ហើយនិងការរួមផ្សំទាំងការប្រើប្រាស់សៀវភៅ និង ឧបករណ៍សំលេង។ លោកអ្នកនឹងមានការទាក់ទងទៀងទាត់តាមទូរស័ព្ទជាមួយគ្រូដែលមានសមត្ថភាព។ លោកអ្នកនឹងចំណាយពេលយ៉ាងតិចប្រាំម៉ោងក្នុងមួយសប្តាហ៍ទៅលើវគ្គសិក្សា។

រាល់លំហាត់ និង សកម្មភាពរួមមានការស្តាប់វិទ្យុ អានកាសែត និង ការផ្សាយពាណិជ្ជកម្ម និយាយអំពីខ្លួនឯង សួរព័តមាន បំពេញទំរង់បែបបទ និង ការសរសេរសំបុត្រ។

### គ្រោងការណ៍គ្រូបង្រៀនតាមផ្ទះ

ប្រសិនបើលោកអ្នកមានសិទ្ធិសំរាប់ថ្នាក់ AMEP តែមិនអាចនៅរៀនបានទេ លោកអ្នកអាចរៀនជាមួយគ្រូបង្រៀននៅតាមផ្ទះ។

គ្រូបង្រៀនតាមផ្ទះអាចពិភាក្សាជាមួយលោកអ្នកអំពីវិធីដ៏ល្អបំផុតសំរាប់លោកអ្នកដើម្បីរៀនភាសាអង់គ្លេសនិងអាចជួយលោកអ្នកស្វែងយល់ពីជីវិតប្រចាំថ្ងៃនៅប្រទេសអូស្ត្រាលី។

ស្ថាប័នផ្តល់កិច្ចបំរើ AMEP អាចផ្តល់ព័តមានបន្ថែមអំពីគ្រោងការនេះ

## មុននឹងចាប់ផ្តើមរៀនថ្នាក់ AMEP

មុននឹងចាប់ផ្តើមរៀនថ្នាក់ AMEP លោកអ្នកត្រូវធ្វើការណាត់ជួបជាមួយមជ្ឈមណ្ឌល AMEP របស់លោកអ្នកដើម្បី ៖

- វាយតំលៃកំរិតភាសាអង់គ្លេសរបស់លោកអ្នក
- ព្រមព្រៀងអំពីចំនួនម៉ោងដែលអ្នកត្រូវរៀនក្នុងសប្តាហ៍នីមួយៗនិងប្រភេទថ្នាក់រៀនដែលលោកអ្នកនឹងត្រូវរៀន
- ពិភាក្សាអំពីតំរូវការការមើលថែកុមារនិងពីអ្វីដែលមជ្ឈមណ្ឌល AMEP អាចជួយដល់លោកអ្នកបាន
- កំនត់មាគ៌ារៀងៗខ្លួនសំរាប់គោលដៅអប់រំនិងវិជ្ជាជីវះហើយកំនត់នូវអ្វីដែលលោកអ្នកត្រូវធ្វើនិងសិក្សាដើម្បីសំរេចគោលដៅទាំងនោះ។ ការរីកចំរើនឆ្ពោះទៅកាន់គោលដៅរបស់លោកអ្នកនឹងត្រូវបានថតចំលងទុកនៅពេលដែលលោកអ្នកសិក្សាភាសាអង់គ្លេសកាន់តែខ្ពស់។

## សំរាប់ពត៌មានបន្ថែម

សំរាប់ពត៌មានបន្ថែមលោកអ្នកអាចទូរស័ព្ទទៅកាន់ក្រសួង អន្តោប្រវេសន៍និងការចូលសញ្ជាតិតាមរយៈលេខ 131 881 (តំលៃហៅដូចក្នុងតំបន់ពីគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី)

ពត៌មានអំពី AMEP រួមទាំងស្ថាប័នផ្តល់កិច្ចបំរើដែលនៅជិតលោកអ្នកជាងគេ អាចរកឃើញនៅត្រង់វ៉ិបសាយ www.immi.gov.au/amep

ប្រសិនបើលោកអ្នកត្រូវការជំនួយការបកប្រែ ចូរទំនាក់ទំនងកិច្ចបំរើជាតិផ្នែកបកប្រែភាសាសរសេរនិងនិយាយ (TIS) តាមរយៈលេខ 131 450 (តំលៃហៅចូលដូចក្នុងតំបន់ពីគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី) ។ កន្លែងនេះផ្តល់កិច្ចបំរើបកប្រែភាសាសរសេរនិងនិយាយ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍